កិច្ចព្រមព្រៀង

រវាង

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

និង

រដ្ឋាភិបាលនៃសាធារណរដ្ឋអេស្វាម៉ារ

ស្តីពី

ការលើកលែងពន្ធដារការពារចំពោះអ្នកកាន់លិខិតឆ្លងដែនការទូត និងផ្លូវការ

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋអេស្វាម៉ារ (ដែលរំពឹងតទៅហៅថា "**ភាគីចុះកិច្ចសន្យា**")

ដោយមានបំណងពង្រឹងចំណងមិត្តភាព និងសហប្រតិបត្តិការរវាងប្រទេសទាំងពីរ

ដោយទទួលស្គាល់នូវភាពចាំបាច់ ក្នុងការសំរួលដល់ការធ្វើដំណើរចូលក្នុងទឹកដី នៃប្រទេសរៀងៗខ្លួន ចំពោះមន្ត្រីនៃប្រទេសទាំងពីរ ដែលកាន់លិខិតឆ្លងដែនការទូត និងផ្លូវការ

បានព្រមព្រៀងគ្នាដូចតទៅ:

មាត្រា ១

ពលរដ្ឋនៃភាគីនិមួយៗ ដែលកាន់លិខិតឆ្លងដែនការទូត និងផ្លូវការ មានសុពលភាព មិនមែនជាអ្នករស់នៅក្នុងទឹកដីនៃភាគីម្ខាងទៀត ត្រូវបានអនុញ្ញាតអោយចូល ឆ្លងកាត់ ស្នាក់នៅ និងចេញពីទឹកដី នៃភាគីចុះកិច្ចសន្យាម្ខាងទៀត ដោយពុំមានទិដ្ឋាការ ក្នុងរយៈពេលមិនលើសពី ៣០ថ្ងៃ ចាប់ពីថ្ងៃចូល ។

មាត្រា ២

ការពន្យារយៈពេលស្នាក់នៅ ដែលមានចែងក្នុងមាត្រា១ ត្រូវបានផ្តល់ឱ្យដោយអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេសម្ចាស់ផ្ទះ តាមការស្នើសុំជាលាយលក្ខ័អក្សររបស់ស្ថានបេសកកម្មការទូត ឬប៉ុស្តិ៍កុងស៊ុល នៃរដ្ឋដាក់ទូត ។

មាត្រា ៣

ក្នុងករណីពុំមានស្ថានបេសកកម្មការទូត ឬប៉ុស្តិ៍កុងស៊ុល នៃភាគីចុះកិច្ចសន្យា អ្នកកាន់លិខិតឆ្លងដែនការទូត ឬផ្លូវការ ត្រូវស្នើសុំទៅនាយកដ្ឋានកុងស៊ុលនៃក្រសួងការបរទេសនៃរដ្ឋម្ចាស់ផ្ទះ ។

មាត្រា ៤

ពលរដ្ឋនៃភាគីនីមួយៗ ដែលកាន់លិខិតឆ្លងដែនការទូត និងផ្លូវការ ដែលជាសមាជិកនៃបេសកកម្ម ការទូត ស្ថានីកុងស៊ុល ឬតំណាងនៃអង្គការអន្តរជាតិ ដែលតាំងនៅក្នុងទឹកដីនៃភាគីម្ខាងទៀត ព្រមទាំងសមាជិក គ្រួសារក្នុងបន្ទុក ដែលរស់នៅជាមួយពួកគេ និងកាន់លិខិតឆ្លងដែនការទូត ផ្លូវការ មានសុពលភាព ត្រូវបានអនុញ្ញាតឱ្យចូល ឆ្លងកាត់ ស្នាក់នៅ និងចេញពីទឹកដីនៃភាគីម្ខាងទៀត ដោយពុំចាំបាច់មានទិដ្ឋាការ ក្នុងអំឡុងពេលបំពេញភារៈកិច្ច ដោយត្រូវអនុវត្តតាមលក្ខខ័ណ្ឌតំរូវរបស់ភាគីម្ខាងទៀត ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីពួកគេចូលក្នុងទឹកដីនៃភាគីម្ខាងទៀត ។

មាត្រា ៥

ពលរដ្ឋដែលបានពិពណ៌នាក្នុងកិច្ចព្រមព្រៀងនេះ អាចចូល ឆ្លងកាត់ និងចាកចេញពីទឹកដីនៃភាគីម្ខាងទៀត តាមគ្រប់ច្រកព្រំដែន ដែលបើកសំរាប់អ្នកដំណើរអន្តរជាតិ ។

មាត្រា ៦

ពលរដ្ឋនៃភាគីនីមួយៗ ត្រូវអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិនានាដែលនៅជរមាន ក្នុងរយៈពេលស្នាក់នៅក្នុងទឹកដីនៃភាគីម្ខាងទៀត ។

មាត្រា ៧

កិច្ចព្រមព្រៀងនេះ មិនកំរិតសិទ្ធិរបស់ភាគីនីមួយៗ ក្នុងការបដិសេធមិនឱ្យចូល ឬកាត់បន្ថយរយៈពេលស្នាក់នៅ របស់ពលរដ្ឋនៃភាគីម្ខាងទៀត ដែលត្រូវបានចាត់ទុកថា មិនគួរគប្បី ។

មាត្រា ៨

១. ភាគីចុះកិច្ចសន្យាត្រូវធ្វើការផ្លាស់ប្តូរ តាមផ្លូវការទូត នូវគំរូលិខិតឆ្លងដែនការទូត និងផ្លូវការ របស់ខ្លួន ដែលបានរៀបរាប់នៅក្នុងកិច្ចព្រមព្រៀងនេះ មិនឱ្យយឺតជាង ៣០ថ្ងៃ បន្ទាប់ពីថ្ងៃចុះហត្ថលេខានៃកិច្ចព្រមព្រៀងនេះ ។

២. ក្នុងករណីមានការចេញលិខិតឆ្លងដែនការទូត និងផ្លូវការថ្មី ឬមានការកែប្រែលិខិតឆ្លងដែន ដែលកំពុងប្រើប្រាស់ ភាគីចុះកិច្ចសន្យាត្រូវជូនព័ត៌មានភ្លាមទៅវិញទៅមក តាមផ្លូវការទូត អំពីគំរូនៃលិខិតឆ្លងដែនទាំងនោះ ដោយភ្ជាប់ជាមួយនូវព័ត៌មានពាក់ព័ន្ធលំអិត មិនឱ្យតិចជាង ៣០ថ្ងៃ មុនពេលដាក់ឱ្យប្រើប្រាស់ ។

មាត្រា ៩

ភាគីនីមួយៗ អាចផ្អាកបណ្តោះអាសន្ន ការអនុវត្តកិច្ចព្រមព្រៀងនេះទាំងស្រុង ឬលើផ្នែកខ្លះ ដោយហេតុផល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ឬសុខភាពសាធារណៈ ។ ការផ្អាកបណ្តោះអាសន្ន ក៏ដូចជា ការលុបចោល ត្រូវជូនព័ត៌មានទៅភាគីម្ខាងទៀតឱ្យបានឆាប់បំផុត តាមដែលអាចធ្វើបាន តាមផ្លូវការទូត ។

មាត្រា ១០

រាល់វិវាទទាំងឡាយដែលកើតចេញពីការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងនេះ ត្រូវដោះស្រាយដោយមិត្តភាព តាមរយៈការផ្លាស់ប្តូរយោបល់ និងការចរចារ រវាងភាគីចុះកិច្ចសន្យា ។

មាត្រា ១១

១. កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមាន ៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃកំណត់ទូតទី ២ ដែលភាគីតូសន្យាមួយជូនព័ត៌មានអំពីការបានបំពេញលក្ខខ័ណ្ឌតម្រូវផ្ទៃក្នុងរបស់ខ្លួន ។

២. កិច្ចព្រមព្រៀងនេះ អាចធ្វើវិសោធនកម្ម និងបំពេញបន្ថែម ជាលាយលក្ខអក្សរ ដោយការព្រមព្រៀងគ្នារវាងភាគីចុះកិច្ចសន្យា តាមផ្លូវការទូត ។

៣. កិច្ចព្រមព្រៀងនេះ ត្រូវនៅជាធរមាន ប្រសិនបើពុំមានភាគីណាមួយប្រកាសលុបចោល តាមផ្លូវការទូត ។ ការប្រកាសលុបចោលកិច្ចព្រមព្រៀងនេះ នឹងចូលជាធរមានក្នុងរយៈពេល៩០ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានការជូនព័ត៌មាននេះ ។

ធ្វើនៅទីក្រុង ញូវយ៉ក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១២ ជាពីរច្បាប់ដើម ជាភាសា ខ្មែរ អេស្ប៉ាញ និង អង់គ្លេស ដែលអត្ថបទនិមួយ១មានតំលៃស្មើគ្នា ។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទភាសាអង់គ្លេស ត្រូវយកជាឯកសារគោល ។

ជ. រដ្ឋាភិបាល	ជ. រដ្ឋាភិបាល
នៃព្រះរាជាណាចក្រកម្ពុជា	នៃសាធារណរដ្ឋអេក្វាឌ័រ
ឯកឧត្តម អ៊ុប បូរិទ្ធ	ឯកឧត្តមបណ្ឌិត ម៉ាកូ ចីនីស៊ីយ៉ូ អាម៉ូយ៉ា ម៉ាធីនេ
រដ្ឋលេខាធិការ	អនុរដ្ឋមន្ត្រី
ក្រសួងការបរទេសនិង	ក្រសួងការបរទេសនិង
សហប្រតិបត្តិការអន្តរជាតិ	សមាហរណកម្មនយោបាយ